វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ០២ ប្រកន.០៣/ *ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣*

**ប្រកាស អន្តរក្រសួង**

**ស្តីពីការ កំណត់សារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី**

**រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/សន/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង រៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត.ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- តាមសំណើរបស់គណៈកម្មការសុរិយោដីខេត្តព្រះវិហារ

**សំរេច**

**ប្រការ ១ :** វិវាទដីធ្លីទាំងឡាយត្រូវបានបែងចែកទៅតាមសមត្ថកិច្ចទីមួយៗដូចតទៅ :

- វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាល សុរិយោដី ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ ។
- វិវាទដីធ្លីដែលមានទាន់បានចុះបញ្ជីសុរិយោដី គឺជាដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញ ដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្នុងសមត្ថកិច្ចគណៈកម្មការសុរិយោដី ។

Downloaded from http://www.khmerlaws.com

**ប្រការ ២ :** តុលាការគ្រប់ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ដែលជាសមត្ថកិច្ចរបស់គណៈកម្មការ សុរិយោដីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៣:** បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួល និងកំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះ តុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ ។

**ប្រការ ៤:** វិវាទអំពីកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជា វិវាទអំពីការបែងចែកមរតក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំ ជាដើម ជាសមត្ថកិច្ចរបស់តុលាការ ។

**ប្រការ ៥:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦: តុលាការគ្រប់ថ្នាក់ អគ្គាធិការដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង ក្រោមឱវាទក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងគណៈកម្មការសុរិយោដីគ្រប់ថ្នាក់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com